នស/រកត/០២១៩/២៥៤

# ព្រះរាជក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរសាលាភូមិន្ទរដ្ឋបាលឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងរៀបចំសាលាភូមិន្ទរដ្ឋបាល ហៅកាត់ «**ស.ភ.រ.**» ជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈចំណុះក្រសួងមុខងារសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលដំបូង ការបណ្តុះបណ្តាលបន្ត និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសាធារណៈ។

បសញ្ញា ស.ភ.រ. មានកំណត់នៅក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី២
## បេសកកម្មនិងមុខងារ

**មាត្រា២ .-**

ស.ភ.រ. មានបេសកកម្ម៖

- ជ្រើសរើសនិងបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ និងផ្តល់ការបណ្តុះបណ្តាលដំបូងដល់មន្ត្រីដែលទើបត្រូវបានជ្រើសរើសថ្មីក្នុងក្របខណ្ឌនៃវិស័យរដ្ឋបាល
- រៀបចំផ្តល់ការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គវិក្រឹត្យការ វគ្គសុក្រឹត្យការ ការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី សន្និសីទ សិក្ខាសាលា និងការរៀបចំកម្មវិធីចែករំលែកចំណេះដឹងនិងបទពិសោធន៍ដល់សិស្ស និស្សិត មន្ត្រីរាជការ មន្ត្រីសាធារណៈ និងមន្ត្រីដទៃទៀតដែលបម្រើការងារក្នុងនិង/ឬពាក់ព័ន្ធនឹងវិស័យសាធារណៈ និង
- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយនវានុវត្តន៍និងឧត្តមានុវត្តន៍លើផ្នែកគោលនយោបាយសាធារណៈ ការគ្រប់គ្រងសាធារណៈ រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងទំនាក់ទំនងអន្តរជាតិ។

**មាត្រា៣ .-**

ស.ភ.រ. បំពេញមុខងារដូចខាងក្រោម៖

- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធលើការរៀបចំ សម្របសម្រួល និងការវាយតម្លៃតម្រូវការធនធានមនុស្សក្នុងវិស័យសាធារណៈ ព្រមទាំងការរៀបចំផែនការនិងការអនុវត្តកម្មវិធីបណ្តុះបណ្តាល
- រៀបចំការប្រឡងប្រជែងជ្រើសរើសនិងការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ ព្រមទាំងរៀបចំវគ្គត្រៀមសម្រាប់ការប្រឡងប្រជែង
- រៀបចំការបណ្តុះបណ្តាលតម្រង់ទិសដំបូងសម្រាប់មន្ត្រីដែលទើបត្រូវបានជ្រើសរើសថ្មីក្នុងក្របខណ្ឌនៃវិស័យរដ្ឋបាល(ក្របខណ្ឌ **ក** និង ក្របខណ្ឌ **ខ**)
- រៀបចំការជ្រើសរើសនិងការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈដល់មន្ត្រីរាជការ មន្ត្រីសាធារណៈ និងមន្ត្រីដទៃទៀត ដែលកំពុងបំពេញការងារនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនឹងសេវាសាធារណៈ តាមរយៈវគ្គវិក្រឹត្យការ វគ្គសុក្រឹត្យការ និងវគ្គបណ្តុះបណ្តាលជំនាញ ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី ឱ្យអាចបំពេញការងារស្របតាមការវិវត្តន៍ថ្មីៗរបស់រដ្ឋបាលសាធារណៈនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ផ្តល់អាហារូបករណ៍សម្រាប់ការសិក្សានៅ ស.ភ.រ. ដល់សិស្ស កម្មសិក្សាការី មន្ត្រីរាជការ និងមន្ត្រីដទៃទៀត ព្រមទាំងជ្រើសរើសនិងផ្តល់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យសាធារណៈ ផ្អែកលើកិច្ចសហការនិងឧបត្ថម្ភធនពីក្រសួង ស្ថាប័ន និងអង្គភាពរបស់រដ្ឋ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍
- សហការជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គ្រឹះស្ថានបណ្តុះបណ្តាលជាតិនិងអន្តរជាតិ ព្រមទាំងជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការរៀបចំកម្មវិធីសិក្សា វគ្គបណ្តុះបណ្តាល កម្មវិធីផ្លាស់ប្តូរសាស្ត្រាចារ្យ មន្ត្រី សិស្ស និងកម្មសិក្សាការី ទស្សនកិច្ចសិក្សា កម្មសិក្សា សកម្មភាពសង្គម ការផ្តល់ជំនួយបច្ចេកទេសនិងការសិក្សាស្រាវជ្រាវដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សនិងស្ថាប័នក្នុងវិស័យសាធារណៈ



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

- ផ្តល់ដល់មន្ត្រីរាជការនូវកាលានុវត្តភាពក្នុងការសិក្សា ការកសាងបណ្តាញទំនាក់ទំនងការងារ ការសន្ទនា ការផ្លាស់ប្តូរទស្សនៈ ការកែប្រែផ្នត់គំនិត ការលើកកម្ពស់តម្លៃវិជ្ជាជីវៈនិងគុណធម៌ ការចែករំលែកចំណេះដឹង ទស្សនវិស័យ ឧត្តមានុវត្តន៍ និងនវានុវត្តន៍ពាក់ព័ន្ធនឹងវិស័យសាធារណៈ
- រៀបចំ ចងក្រង និងបោះពុម្ពផ្សាយសៀវភៅសិក្សា ឯកសារពិគ្រោះ ឯកសារស្រាវជ្រាវ ទស្សនាវដ្តី និងព្រឹត្តិបត្រនានាពាក់ព័ន្ធនឹងវិស័យសាធារណៈសម្រាប់ការសិក្សា ការស្រាវជ្រាវ និងការប្រើប្រាស់ក្នុងក្របខណ្ឌការងារ
- រៀបចំសន្និសីទ សិក្ខាសាលា វេទិកា និងព្រឹត្តិការណ៍នានា ដើម្បីឱ្យមានការចែករំលែកចំណេះដឹងផ្នែកទ្រឹស្តីនិងបទពិសោធន៍លើការដឹកនាំនិងគ្រប់គ្រងវិស័យសាធារណៈ
- បណ្តុះបណ្តាលនិស្សិតនិងមន្ត្រីបរទេសតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៣
## សមាសភាពនិងរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៤ .-**

ស.ភ.រ. ត្រូវបានដឹកនាំ និងតម្រង់ទិសដោយក្រុមប្រឹក្សា ស.ភ.រ. ដែលមានសិទ្ធិអំណាចទូលំទូលាយដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌដែលត្រូវកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះនិងអនុក្រឹត្យស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល។

ក្រុមប្រឹក្សា ស.ភ.រ. មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ជាប្រធាន |
| - នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិកស្វ័យប្រវត្តិ |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ០១ រូប សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ០១ រូប សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប សមាជិក |
| - សាស្ត្រាចារ្យឧត្តមសិក្សា ឬ ឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ដែលមានជំនាញផ្នែកគោលនយោបាយ ច្បាប់ រដ្ឋបាល សេដ្ឋកិច្ច ពាណិជ្ជកម្ម ឬ ទំនាក់ទំនងអន្តរជាតិ | ០២ រូបសមាជិក |

នាយក ស.ភ.រ. ពិនិត្យនិងផ្តល់យោបល់លើបេក្ខភាពសម្រាប់មុខតំណែងជាសមាជិកក្រុមប្រឹក្សា ស.ភ.រ. ដែលត្រូវជ្រើសរើសចេញពីសាស្ត្រាចារ្យឧត្តមសិក្សា ឬ ឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ជូនរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានក្រុមប្រឹក្សា ស.ភ.រ. ដើម្បីពិនិត្យនិងសម្រេចក្នុងការលើកសំណើតែងតាំងជាសមាជិកក្រុមប្រឹក្សា ស.ភ.រ.។

ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សា ស.ភ.រ. ត្រូវកំណត់ដោយអនុក្រឹត្យ។ សមាជិកនៃក្រុមប្រឹក្សា ស.ភ.រ. មានអាណត្តិ ៣ (បី)ឆ្នាំ លើកលែងសមាជិកស្វ័យប្រវត្តិ។ សមាជិកក្រុមប្រឹក្សា ស.ភ.រ. អាចត្រូវតែងតាំងបន្តនៅពេលចប់អាណត្តិ។

**មាត្រា៥ .-**

ក្រុមប្រឹក្សា ស.ភ.រ. មានសិទ្ធិអំណាចនិងភារកិច្ចចម្បងៗ ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់ ស.ភ.រ. រួមទាំងគម្រោងថវិកាសម្រាប់កិច្ចដំណើរការរបស់ក្រុមប្រឹក្សា ស.ភ.រ. និងសកម្មភាពដែលមានលក្ខណៈពាណិជ្ជកម្មរបស់ ស.ភ.រ.
- កំណត់គោលការណ៍ពាក់ព័ន្ធនឹងអភិបាលកិច្ច ដំណើរការ និងនីតិវិធីប្រតិបត្តិការរបស់ ស.ភ.រ. ព្រមទាំងប្រព័ន្ធត្រួតពិនិត្យស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ឱ្យឆ្លើយតបតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលនិងអ្នកប្រើប្រាស់សេវា
- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ ស.ភ.រ. ការបង្កើតក្រុមប្រឹក្សាវិន័យ និងសំណើផ្សេងៗរបស់នាយក ស.ភ.រ. ពាក់ព័ន្ធនឹងការអនុវត្តបេសកកម្មនិងមុខងាររបស់ ស.ភ.រ.
- ពិនិត្យនិងអនុម័តកម្មវិធីបណ្តុះបណ្តាល និងបែបបទរៀបចំការប្រឡងនិងសមាសភាពគណៈមេប្រយោគនានាសម្រាប់ការប្រឡងប្រជែងចូលសិក្សានៅ ស.ភ.រ.
- អនុម័តសំណើបង្កើតវិទ្យាស្ថាន មជ្ឈមណ្ឌល បេក្ខភាពសម្រាប់ការតែងតាំងដែលត្រូវបានកំណត់ដោយព្រះរាជក្រឹត្យនេះ និងគម្រោងនានាដែល ស.ភ.រ. ត្រូវចុះហត្ថលេខាក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានជាតិឬអន្តរជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងនិងសមិទ្ធកម្មរបស់ ស.ភ.រ. រួមមានការពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ ស.ភ.រ. អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់ ដើម្បីសម្រេចបេសកកម្ម មុខងារ និងការប្រព្រឹត្តទៅរបស់ ស.ភ.រ។

**មាត្រា៦ .-**

នាយក ស.ភ.រ. មានភារកិច្ចដឹកនាំនិងគ្រប់គ្រងប្រតិបត្តិការរបស់ ស.ភ.រ. អមដោយនាយករងមួយចំនួនអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ នាយក ស.ភ.រ. ត្រូវទទួលបន្ទុកដឹកនាំ គ្រប់គ្រង និងចាត់ចែងមន្ត្រីរាជការស៊ីវិលចាប់ពីថ្នាក់នាយករង ស.ភ.រ. ចុះមកនិងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងទីប្រឹក្សា និងជំនួយការជាតិនិងអន្តរជាតិដែលបំពេញការងារនៅ ស.ភ.រ. អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយក ស.ភ.រ. ត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ។ បេក្ខភាពនាយក ស.ភ.រ. ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមឥស្សរជនជាន់ខ្ពស់ ដែលមានកម្រិតវប្បធម៌ចាប់ពីថ្នាក់ក្រោយឧត្តមសិក្សាឡើងទៅក្នុងផ្នែកគោលនយោបាយ ច្បាប់ គ្រប់គ្រង រដ្ឋបាល សេដ្ឋកិច្ច ពាណិជ្ជកម្ម ឬទំនាក់ទំនងអន្តរជាតិ ព្រមទាំងត្រូវមានបទពិសោធន៍ក្នុងការងារវិស័យសាធារណៈរួមមានការងារដឹកនាំគ្រប់គ្រងអង្គភាពសាធារណៈ និងការបណ្តុះបណ្តាលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំ និងមានចំណេះដឹងភាសាអង់គ្លេសកម្រិតខ្ពស់។ បេក្ខភាពនាយក ស.ភ.រ. ត្រូវស្នើដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

នាយករង ស.ភ.រ. ត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ។ បេក្ខភាពនាយករង ស.ភ.រ. ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការស៊ីវិល ដែលមានកម្រិតវប្បធម៌ចាប់ពីថ្នាក់ក្រោយឧត្តមសិក្សា ឬកម្រិតបណ្តុះបណ្តាលប្រហាក់ប្រហែលឡើងទៅ និងមានបទពិសោធន៍ក្នុងការងារវិស័យសាធារណៈយ៉ាងតិច១០(ដប់)ឆ្នាំ។ នាយក ស.ភ.រ. ពិនិត្យនិងផ្តល់យោបល់លើបេក្ខភាពនាយករង ស.ភ.រ. ជូនរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានក្រុមប្រឹក្សា ស.ភ.រ. ពិនិត្យនិងសម្រេចលើការលើកសំណើតែងតាំង។

**មាត្រា៧**.-

ស.ភ.រ. ត្រូវមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានសមាសភាពដូចតទៅ៖

- នាយក ស.ភ.រ. ជាប្រធាន
- នាយករង ស.ភ.រ. សមាជិកស្វ័យប្រវត្តិ
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ដែលជាសមាជិកក្រុមប្រឹក្សា ស.ភ.រ. សមាជិកស្វ័យប្រវត្តិ
- សាស្ត្រាចារ្យឧត្តមសិក្សា ឬ ឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ដែលជាសមាជិកក្រុមប្រឹក្សា ស.ភ.រ. សមាជិកស្វ័យប្រវត្តិ
- ប្រធាននាយកដ្ឋាន/អង្គភាពចំណុះ ស.ភ.រ. សមាជិកស្វ័យប្រវត្តិ
- តំណាងសាកលវិទ្យាល័យឬវិទ្យាស្ថានបណ្តុះបណ្តាលរដ្ឋឬឯកជន យ៉ាងច្រើន ០៣ រូបជាសមាជិក (សាកលវិទ្យាល័យឬវិទ្យាស្ថានបណ្តុះបណ្តាលអាចមានតំណាងតែមួយរូបប៉ុណ្ណោះក្នុងក្រុមប្រឹក្សា)
- សាស្ត្រាចារ្យ ស.ភ.រ. ដែលមានជំនាញលើផ្នែកគោលនយោបាយ ច្បាប់ គ្រប់គ្រង រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬទំនាក់ទំនងអន្តរជាតិ និង បុគ្គលឆ្នើមក្នុងវិស័យសាធារណៈ ឬ វិស័យឯកជន សមាជិក

ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រ ស.ភ.រ. ក្រៅពីសមាជិកស្វ័យប្រវត្តិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានក្រុមប្រឹក្សា ស.ភ.រ.។ នាយក ស.ភ.រ. ពិនិត្យនិងលើកសំណើជូនក្រុមប្រឹក្សា ស.ភ.រ. ពិនិត្យនិងសម្រេចលើបេក្ខភាពសម្រាប់មុខតំណែងជាសមាជិកក្រុមប្រឹក្សាវិទ្យាសាស្ត្រ ដែលត្រូវជ្រើសរើសចេញពីតំណាងសាកលវិទ្យាល័យ ឬ វិទ្យាស្ថានបណ្តុះបណ្តាល សាស្ត្រាចារ្យ ស.ភ.រ. និងបុគ្គលឆ្នើមក្នុងវិស័យសាធារណៈ ឬ វិស័យឯកជន។

សមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រ ស.ភ.រ. មានអាណត្តិ ៣(បី)ឆ្នាំ លើកលែងតែសមាជិកស្វ័យប្រវត្តិ។ សមាជិកក្រុមប្រឹក្សាវិទ្យាសាស្ត្រ ស.ភ.រ. អាចត្រូវតែងតាំងបន្តនៅពេលចប់អាណត្តិ។

**មាត្រា៨**.-

ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ស.ភ.រ. មានមុខងារដូចខាងក្រោម៖

- រៀបចំនិងដាក់ឱ្យអនុវត្តនូវកម្មវិធីបណ្តុះបណ្តាល កម្មវិធីសិក្សា និងការស្រាវជ្រាវ
- ធានាគុណភាពខ្ពស់បំផុតនៃការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការបោះពុម្ពផ្សាយរបស់ ស.ភ.រ.
- កំណត់លក្ខណៈវិនិច្ឆ័យ ពិនិត្យលក្ខណៈសម្បត្តិ ជ្រើសរើស និងរៀបចំការបំពេញការងាររបស់គ្រូបង្រៀន គ្រូឧទ្ទេស សាស្ត្រាចារ្យ ព្រមទាំងវាគ្មិនផ្សេងៗដើម្បីធានានូវគុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ
- ជំរុញការសិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយករណីសិក្សា ឧត្តមានុវត្តន៍ និងនវានុវត្តន៍ក្នុងវិស័យសាធារណៈ
- ពិនិត្យនិងសម្រេចលើគោលការណ៍នៃការផ្តល់សញ្ញាបត្រ វិញ្ញាបនបត្រ និងពានរង្វាន់ផ្សេងៗក្នុងក្របខណ្ឌនៃការបណ្តុះបណ្តាលនិងស្រាវជ្រាវ
- ផ្តល់យោបល់លើគោលនយោបាយនិងយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលរបស់ ស.ភ.រ.
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សា ស.ភ.រ.។

**មាត្រា៩ ..**

ផ្អែកលើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនិងស្ថាប័នសាធារណៈ និងផ្អែកលើសំណើរបស់ក្រុមប្រឹក្សា ស.ភ.រ. មជ្ឈមណ្ឌល ឬវិទ្យាស្ថានឯកទេស នឹងត្រូវបង្កើតឡើងចំណុះ ស.ភ.រ. ដោយអនុក្រឹត្យ។

**មាត្រា១០ ..**

លក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤

## ការបណ្តុះបណ្តាល

### ផ្នែកទី១

### ការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ

**មាត្រា១១ ..**

ការជ្រើសរើសចូលរៀននៅ ស.ភ.រ. ជាសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង/ឬ ក្នុងចំណោមនិស្សិត។

បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវបានទទួលស្គាល់ជាសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ តាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ ចំពោះមន្ត្រីរាជការដែលប្រឡងជាប់ជាសិស្សមន្ត្រីជាន់ខ្ពស់ឬសិស្សមន្ត្រីក្រមការ ត្រូវបានរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង និងការចូលនិវត្តន៍ ព្រមទាំងរក្សាមុខតំណែងក្នុងអង្គភាពដើម។

ស.ភ.រ. រៀបចំប្រឡងប្រជែងជ្រើសរើសនិងបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ អនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លក្ខខណ្ឌតម្រូវដោយលក្ខន្តិកៈដោយឡែក និងផ្អែកលើផែនការក្របខណ្ឌរបស់រាជរដ្ឋាភិបាល។

បេក្ខជនដែលប្រឡងចូលជាសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវមានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រ ឬសមមូលនឹងបរិញ្ញាបត្រ និងត្រូវទទួលការបណ្តុះបណ្តាលយ៉ាងតិច១៨(ដប់ប្រាំបី)ខែនៅ ស.ភ.រ.។ សិស្សមន្ត្រីជាន់ខ្ពស់ដែលទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យ នឹងទទួលបានសញ្ញាបត្រមន្ត្រីជាន់ខ្ពស់។

បេក្ខជនប្រឡងចូលជាសិស្សមន្ត្រីក្រមការ ត្រូវបានជ្រើសរើសចេញពីបេក្ខជនមានសញ្ញាបត្រទាបបំផុតសមមូលមធ្យមសិក្សាទុតិយភូមិ បូក២(ពីរ)ឆ្នាំនៃការសិក្សាក្នុងកម្រិតឧត្តមសិក្សា និងត្រូវទទួលការបណ្តុះបណ្តាលរយៈពេល១២(ដប់ពីរ)ខែ។ សិស្សមន្ត្រីក្រមការដែលទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យ នឹងទទួលបានសញ្ញាបត្រមន្ត្រីក្រមការ។

ក្នុងករណីកម្មវិធីសិក្សារបស់សិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ មានបញ្ចូលកម្មសិក្សា រយៈពេលកម្មសិក្សានេះនឹងត្រូវរាប់បញ្ចូលជាកម្មសិក្សាសាកល្បងសម្រាប់ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ដោយឡែកសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការដែលជាមន្ត្រីរាជការ មិនត្រូវបានតម្រូវឱ្យធ្វើកម្មសិក្សាឡើងវិញសម្រាប់ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលឡើយ។

**មាត្រា១២ ..**

សិស្សមន្ត្រីជាន់ខ្ពស់ដែលត្រូវបានជ្រើសរើសពីក្នុងចំណោមនិស្សិត ហើយទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យ តាមកម្មវិធីសិក្សាក្នុងរយៈពេលយ៉ាងតិច១៨(ដប់ប្រាំបី)ខែ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ក** ដែលសមស្រប និងផ្តល់៣(បី)ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

សិស្សមន្ត្រីជាន់ខ្ពស់ដែលត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ហើយទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យ តាមកម្មវិធីសិក្សាក្នុងរយៈពេលយ៉ាងតិច១៨(ដប់ប្រាំបី)ខែ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ក** ដែលសមស្រប និងផ្តល់៣(បី)ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល ឬ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ក** និងផ្តល់២(ពីរ)ថ្នាក់បន្ថែមលើថ្នាក់ដែលមានស្រាប់របស់សាមីជនដោយត្រូវរៀបចំផ្អែកលើករណីដែលផ្តល់ប្រយោជន៍ដល់សិស្សមន្ត្រី។

**មាត្រា១៣ ..**

សិស្សមន្ត្រីក្រមការដែលត្រូវបានជ្រើសរើសពីក្នុងចំណោមនិស្សិត ហើយទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យតាមកម្មវិធីសិក្សាក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** ដែលសមស្រប និងផ្តល់២(ពីរ)ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល ចំពោះអ្នកមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក ២(ពីរ)ឆ្នាំនៃការសិក្សាបន្ថែមនៅឧត្តមសិក្សា និងផ្តល់ ៣(បី)ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល ចំពោះអ្នកមានបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ។

សិស្សមន្ត្រីក្រមការដែលត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ហើយទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យតាមកម្មវិធីសិក្សាក្នុងរយៈពេលយ៉ាងតិច១២(ដប់ពីរ)ខែ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** ដែលសមស្រប ដោយផ្តល់ថ្នាក់ដូចលក្ខខណ្ឌដែលមានកំណត់ក្នុងវាក្យខណ្ឌទី១ នៃមាត្រា១៣នេះ ឬ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** និងផ្តល់២(ពីរ)ថ្នាក់បន្ថែមលើថ្នាក់ដែលមានស្រាប់របស់សាមីជន ដោយត្រូវរៀបចំផ្អែកលើករណីដែលផ្តល់ប្រយោជន៍ដល់សិស្សមន្ត្រី។

## ផ្នែកទី២
## ការបណ្តុះបណ្តាលតម្រង់ទិសដំបូង
## សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងសិស្សក្រមការ

**មាត្រា១៤ ..**

បេក្ខជនដែលទើបត្រូវបានជ្រើសរើសថ្មីបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៃវិស័យរដ្ឋបាល (ក្របខណ្ឌ **ក** និងក្របខណ្ឌ **ខ**)ត្រូវទទួលការបណ្តុះបណ្តាលតម្រង់ទិសដំបូងនៅសាលាភូមិន្ទរដ្ឋបាល ដែលមានរយៈពេលត្រឹម៣(បី)ខែ ឬមិនលើសពី ២០០(ពីររយ)ម៉ោង មុនពេលចាប់ផ្តើមអនុវត្តកម្មសិក្សានៅតាមក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល។ ក្នុងអំឡុងពេលនៃការសិក្សា បេក្ខជនត្រូវបានទទួលស្គាល់ជាសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងសិស្សក្រមការនៃវគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូង តាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ រយៈពេលបណ្តុះបណ្តាលតម្រង់ទិសដំបូងនេះ ត្រូវបានរាប់បញ្ចូលជារយៈពេលនៃការធ្វើកម្មសិក្សាសាកល្បងសម្រាប់ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងសិស្សក្រមការ ដែលទទួលការបណ្តុះបណ្តាលតម្រង់ទិសដំបូងប្រកបដោយជោគជ័យនឹងទទួលបានវិញ្ញាបនបត្របណ្តុះបណ្តាលតម្រង់ទិសដំបូងមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬវិញ្ញាបនបត្របណ្តុះបណ្តាលតម្រង់ទិសដំបូងមន្ត្រីក្រមការ ផ្អែកលើករណីនីមួយៗ។

ស.ភ.រ. អាចរៀបចំការបណ្តុះបណ្តាលតម្រង់ទិសដំបូងសម្រាប់បេក្ខជនដែលទើបត្រូវបានជ្រើសរើសថ្មីបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៃវិស័យផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា១៥ ..**

ក្រសួងមុខងារសាធារណៈ ត្រូវកំណត់បែបបទនិងនីតិវិធីនៃការបណ្តុះបណ្តាលតម្រង់ទិសដំបូងដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ សម្រាប់បេក្ខជនដែលទើបត្រូវបានជ្រើសរើសថ្មីបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល នៅមុនពេលការដាក់ឱ្យបេក្ខជនប្រឡងជាប់ទាំងនេះអនុវត្តកម្មសិក្សានៅតាមក្រសួង ស្ថាប័ន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៣
## ការបណ្តុះបណ្តាលបន្ត

**មាត្រា១៦** .-

ស.ភ.រ. រៀបចំវគ្គបណ្តុះបណ្តាលបន្តដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនិងមន្ត្រីសាធារណៈដទៃទៀតទៅតាមប្រភេទក្របខណ្ឌនិងមុខតំណែងគ្រប់គ្រងដូចខាងក្រោម៖

- វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ : សម្រាប់មន្ត្រីរាជការដែលកាន់មុខតំណែងចាប់ពីថ្នាក់អភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលារាជធានី ខេត្ត ប្រធានមន្ទីររាជធានី ខេត្ត អនុប្រធាននាយកដ្ឋាន ឬមុខតំណែងប្រហាក់ប្រហែលឡើងទៅ
- វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល : សម្រាប់មន្ត្រីរាជការស្ថិតក្នុងប្រភេទក្របខណ្ឌ **ក** ឬក្របខណ្ឌប្រហាក់ប្រហែល (មិនមានមុខតំណែងគ្រប់គ្រង)
- វគ្គវិក្រឹត្យការមន្ត្រីមធ្យម : សម្រាប់មន្ត្រីរាជការដែលកាន់មុខតំណែងគ្រប់គ្រងចាប់ពីប្រធានការិយាល័យ អភិបាលរងក្រុង ស្រុក ខណ្ឌ នាយករងរដ្ឋបាលសាលារាជធានី ខេត្ត អនុប្រធានមន្ទីររាជធានី ខេត្ត ឬមុខតំណែងប្រហាក់ប្រហែលចុះក្រោម
- វគ្គវិក្រឹត្យការមន្ត្រីក្រមការ : សម្រាប់មន្ត្រីរាជការស្ថិតក្នុងប្រភេទក្របខណ្ឌ **ខ** ឬក្របខណ្ឌប្រហាក់ប្រហែល(មិនមានមុខតំណែងគ្រប់គ្រង)

វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវមានរយៈពេលបណ្តុះបណ្តាលយ៉ាងតិច ៥៥០(ប្រាំរយហាសិប)ម៉ោងឡើង និងវគ្គវិក្រឹត្យការមន្ត្រីមធ្យម និងវគ្គវិក្រឹត្យការមន្ត្រីក្រមការត្រូវមានរយៈពេលបណ្តុះបណ្តាលយ៉ាងតិច ៣៥០(បីរយហាសិប)ម៉ោង។

មន្ត្រីដែលត្រូវបានជ្រើសរើស នឹងត្រូវបានទទួលស្គាល់ជាកម្មសិក្សាការីក្នុងវគ្គវិក្រឹត្យការនីមួយៗដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ មន្ត្រីរាជការស៊ីវិលជាកម្មសិក្សាការីដែលទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យវគ្គវិក្រឹត្យការខាងលើនេះ ត្រូវបានដំឡើងថ្នាក់ចំនួន១(មួយ)ថ្នាក់។

**មាត្រា១៧** .-

ស.ភ.រ. អាចរៀបចំវគ្គបណ្តុះបណ្តាលបន្តរយៈពេលខ្លី លើជំនាញពាក់ព័ន្ធនឹងវិស័យសាធារណៈ ដើម្បីគាំទ្រដល់ការធ្វើបច្ចុប្បន្នភាពចំណេះដឹង និងបង្កើនសមត្ថភាពរបស់មន្ត្រីរាជការ មន្ត្រីសាធារណៈ និងមន្ត្រីផ្សេងទៀត ដែលបំពេញការងារក្នុង និង/ឬ ពាក់ព័ន្ធនឹងវិស័យសាធារណៈ។

ស.ភ.រ. អាចរៀបចំការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត ដោយផ្តល់សញ្ញាបត្រ ឬវិញ្ញាបនបត្រកម្រិតណាមួយផ្សេងក្រៅពីការកំណត់នៃព្រះរាជក្រឹត្យនេះ ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៨ ៈ**

លើកលែងសិស្សនិងមន្ត្រីរាជការដែលបានទទួលការបណ្តុះបណ្តាលផ្អែកតាមមាត្រា១១ មាត្រា១២ និងមាត្រា១៣ នៃព្រះរាជក្រឹត្យនេះ កម្មសិក្សាការីនិងមន្ត្រីរាជការស៊ីវិលក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដំបូង និង/ឬវគ្គបណ្តុះបណ្តាលបន្ត រៀបចំដោយ ស.ភ.រ. មានចំនួនម៉ោងសរុបក្នុងរយៈពេល៣(បី)ឆ្នាំ សមាមាត្រនឹងរយៈពេលនៃកម្មវិធីសិក្សាវគ្គវិក្រឹត្យការនីមួយៗដែលមានកំណត់ក្នុងមាត្រា១៦នៃព្រះរាជក្រឹត្យនេះ នឹងត្រូវបានដំឡើងថ្នាក់ចំនួន១(មួយ)ថ្នាក់។

មន្ត្រីរាជការស៊ីវិលក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានអនុញ្ញាតឱ្យទទួលការបណ្តុះបណ្តាលបន្តនៅ ស.ភ.រ. ត្រូវបានរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង និងការចូលនិវត្តន៍ ព្រមទាំងរក្សាមុខតំណែងក្នុងអង្គភាពដើម។

**មាត្រា១៩ ៈ**

ការដាក់ឱ្យអនុវត្តការបណ្តុះបណ្តាលដែលមានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ តាមសំណើរបស់នាយក ស.ភ.រ.។

## ជំពូកទី៥
## ទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុ ស.ភ.រ.

**មាត្រា២០ ៈ**

ស.ភ.រ. មានថវិកាស្វយ័តសម្រាប់គាំទ្រដំណើរការរបស់ខ្លួន ដែលជាកញ្ចប់ថវិកាផ្ទាល់ដោយឡែកក្នុងថវិការបស់ក្រសួងមុខងារសាធារណៈ។

ស.ភ.រ. មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងធនធានដែលបានពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ចំណូលដែលកើតចេញពីសកម្មភាព ស.ភ.រ. អំណោយរបស់រដ្ឋ អំណោយឬអច្ច័យទានរបស់ឯកជន សមាគម និងអង្គការក្រៅរដ្ឋាភិបាល និងពីប្រភពផ្សេងៗ សម្រាប់ចំណាយលើការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់សេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការឧបត្ថម្ភផ្សេងៗតាមការចាំបាច់ ក្នុងគោលដៅធានាការបំពេញបេសកកម្មនិងមុខងាររបស់ ស.ភ.រ.។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុ ស.ភ.រ. ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២១ ៈ**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល និងព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃពុធ ១រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៩

នស/រកត.០២១៩.[illegible]

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៤
ថ្ងៃ ពុធ ១៣កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០១៩

# រូបសញ្ញានៃសាលាភូមិន្ទរដ្ឋបាល

ទម្រង់និមិត្តសញ្ញាសាលាភូមិន្ទរដ្ឋបាលមានរាងជាប្រលេឡូក្រាមបញ្ឈរ តំណាងឱ្យផ្នែកមួយនៃការបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពដឹកនាំ គ្រប់គ្រង ប្រតិបត្តិការ និងសហការក្នុងវិស័យសាធារណៈរបស់មន្ត្រីមកពីគ្រប់ក្រសួង ស្ថាប័ន។ ជ្រុងទាំងបួនក៏តំណាងឱ្យការបណ្តុះបណ្តាលរបស់សាលាឈរលើបាវចនា "វិន័យ គុណភាព គុណធម៌ និងនវានុវត្តន៍" និង ការបណ្តុះព្រហ្មវិហារធម៌ "មេត្តា ករុណា មុទិតា និងឧបេក្ខា" ដល់មន្ត្រី។ និមិត្តសញ្ញាណនេះ ក៏មានការរចនានិងការបង្កប់នូវអត្ថន័យផងដែរ ដូចខាងក្រោម៖

- រូបមកុដនៅចំផ្នែកកណ្តាលមានពន្លឺជះរស្មី តំណាងស្ថាប័នព្រះមហាក្សត្រ ដែលផ្តល់នូវភាពសុខសាន្តជាម្លប់ដ៏ត្រជាក់ដល់មន្ត្រីនិងប្រជានុរាស្ត្រទូទាំងប្រទេស
- នៅលើចុងមកុដមានចារឹកអក្សរ ខម ធំៗ រាងពាក់កណ្តាលរង្វង់មូល ថា "សាលាភូមិន្ទរដ្ឋបាល"
- ចន្លោះក្រោមមកុដមានរូបសៀវភៅ តំណាងរដ្ឋធម្មនុញ្ញនិងក្បួនច្បាប់ទាំងឡាយដែលជាប្រភពនៃគោលការណ៍ រូបមន្ត ទ្រឹស្តី ទស្សនវិទ្យា ជាមូលដ្ឋានសម្រាប់បង្ហាត់បង្រៀន
- អក្សរកាត់"ស ភ រ"មានន័យពេញគឺ សាលាភូមិន្ទរដ្ឋបាល ត្រូវបានចារឹកលើសៀវភៅបើកទំព័រពាក់កណ្តាល
- នៅក្រោមសៀវភៅមានក្បាច់ភ្ញី តំណាងឱ្យវប្បធម៌ជាតិពីបុរាណប្រកបដោយអរិយធម៌ដ៏ថ្កុំថ្កើង
- នៅក្រោមមកុដ និងក្បាច់បុរាណ ត្រូវទ្រដោយត្របកផ្កាឈូក រាងស្នែងក្របី ដែលទ្រដោយក្បាច់ល្បូកតំណាងការបូជាព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ សម្រាប់ប្រតិបត្តិនូវក្រមសីលធម៌ វិន័យ គុណធម៌ ដែលសាលាភូមិន្ទរដ្ឋបាលមានមុខងារអប់រំនិងពង្រឹងបន្ថែម
- ផ្ទៃទាំងមូលនៃនិមិត្តសញ្ញាមានពណ៌បៃតងស្រស់តំណាងឱ្យបញ្ញាញាណនៃសិស្សនិងកម្មសិក្សាការីទាំងឡាយ ដែលបានទទួលការបណ្តុះបណ្តាល គឺជាសមិទ្ធផលដ៏សំខាន់សម្រាប់ប្រើប្រាស់ សម្រេចស្នាដៃក្នុងកិច្ចការសាធារណៈដើម្បីជំរុញការអភិវឌ្ឍសង្គមឥតឈប់ឈរ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL